00195886

C22/I/38

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
# នៅចំពោះមុខអង្គបុរេជំនុំជម្រះ

សំណុំរឿងលេខ ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ស.ច.ស (អ.ប.ជ ០៣)
បញ្ជូនទៅ ៖ អង្គបុរេជំនុំជម្រះ
កាលបរិច្ឆេទនៃការបញ្ជូន៖ ១៦ មិថុនា ២០០៨
ភាគីបញ្ជូន ៖ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី
ភាសាដើម ៖ ខ្មែរ និងអង់គ្លេស
ប្រភេទឯកសារ ៖ សាធារណៈ

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 16, JUNE, 2008
ម៉ោង (Time/Heure): 08:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. FRY

---

## ការសង្កេតជាទូទៅរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

---

បញ្ជូនដោយ ៖
សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី
លោក ហុង គឹមសួន
លោក យុង ផានិត
លោក គង់ ពិសី
លោក ឡោ ជុនធី
លោក នី ចាន់ឌី
កញ្ញា Silke Studzinsky

គោរពជូន ៖
អង្គបុរេជំនុំជម្រះ
លោក ប្រាក់ គឹមសាន
លោក Rowan DOWNING
លោក ន័យ ថុល
លោកស្រី Katinka LAHUIS
លោក ហួត វុទ្ធី

ចម្លងជូន ៖
ការិយាល័យ សហព្រះរាជអាជ្ញា
លោកស្រី ជា លាង
លោក Robert PETIT
ការិយាល័យ សហចៅក្រមស៊ើបអង្កេត
លោក យូ ប៊ុនឡេង
លោក Marcel LEMONDE

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certifified Date/Date de certification): 16 / 06 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

សហមេធាវីការពារ ជនត្រូវចោទ កាំង ហ្គេចអ៊ាវ

លោក ការ សាវុត្ថ

លោក François Roux

សហមេធាវីការពារ ជនត្រូវចោទ នួន ជា

លោក សុន អារុណ

លោក Michel Pestman

លោក Victor Koppe

សហមេធាវីការពារ ជនត្រូវចោទ អៀង សារី

លោក អាង ឧត្តម

លោក Michael G. Karnavas

សហមេធាវីការពារ ជនត្រូវចោទ អៀង ធីរិទ្ធ

លោក ផាត់ ពៅស៊ាង

លោកស្រី Diana Ellis

សហមេធាវីការពារ ជនត្រូវចោទ ខៀវ សំផន

លោក សាយ បូរី

លោក Jacques Vergès

00195888



## I. សេចក្តីផ្តើម

១. នៅក្នុងដំណើរការនីតិវិធីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) ដើមបណ្តឹងរដ្ឋប្បវេណីចូលរួមក្នុងនាមជាគូភាគី ហើយពួកគេមានសិទ្ធិស្មើគ្នាសមទៅនឹងតួនាទីរបស់ខ្លួន ដូចគ្នាទៅនឹងជនត្រូវចោទ និងអយ្យការ។

វិធាន ២៣ (១) នៃវិធានផ្ទៃក្នុងចែងថា គោលបំណងនៃបណ្តឹងរដ្ឋប្បវេណីគឺ ៖

ក. ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំង នឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុង យុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់ និង

ខ. អនុញ្ញាតឱ្យជនរងគ្រោះអាចស្វែងរកសំណងផ្លូវចិត្ត និងសម្ភារភាព ដូចបានចែងក្នុងវិធាននេះ។

២. វិធាននេះបានផ្តល់ដល់ដើមបណ្តឹងរដ្ឋប្បវេណីនូវសិទ្ធិចូលរួមយ៉ាងសកម្មក្នុងដំណើរការនីតិវិធីក្តី ។ វិធាន នេះទទួលស្គាល់ថាដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមចំណែកយ៉ាងសំខាន់ ។ ដូច្នេះដើមបណ្តឹងរដ្ឋប្បវេណីត្រូវបាន អនុញ្ញាតិឱ្យបង្ហាញសេចក្តីថ្លែងការណ៍នៅមុខតុលាការ[1] ពួកគេអាចត្រូវបានផ្តល់សិទ្ធិអំណាចឱ្យសួរសំណួរទៅ ជន ត្រូវចោទ[2] និងសាក្សី[3] ពួកគេមានសិទ្ធិពេញលេញដើម្បីទទួលពត៌មាន[4] មានសិទ្ធិក្នុងការពិនិត្យសំណុំរឿងក្តីតាមរយៈមេធាវីរបស់ខ្លួន[5] និង មានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសំរេចរបស់សហចៅក្រមស៊ើបសួរ[6]។

៣. វិធាន ២១ នៃ វិធានផ្ទៃក្នុងចែងថា ៖

(១) ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំ អនុវត្ត និង បទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍ របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវ

1 មាត្រា៣២៦ វាក្យខ័ណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។
2 មាត្រា១៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។
3 មាត្រា១៥៣ វាក្យខ័ណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។
4 ប្រៀបធៀបជាមួយមាត្រា១៧០ មាត្រា២៤៦ និង ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។
5 វិធាន៧៧ (៤) និង៨៦ នៃវិធានផ្ទៃក្នុង ។
6 ប្រៀបធៀបជាមួយវិធាន៧៤(៤) នៃវិធានផ្ទៃក្នុង ។

00195889



ច្បាប់ និងកិច្ចដំណើរការ នីតិវិធីប្រកបដោយតម្លាភាពដោយគិតដល់លក្ខណៈពិសេស របស់អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ដូចមាន ចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ ៖

ក. ដំណើរការនីតិវិធីនៃអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។ នីតិវិធីត្រូវធានា ឱ្យបាននូវភាព ដាច់ដោយឡែកពីគ្នារវាងអាជ្ញាធរដែលទទួលបន្ទុកការចោទប្រកាន់ និងអាជ្ញាធរដែល ទទួលបន្ទុកការវិនិច្ឆ័យទោស។

ខ. (........)

គ. អង្គជំនុំជម្រះវិសាមញ្ញត្រូវធានាថាជនរងគ្រោះត្រូវទទួលបានការជូនពត៌មាន ហើយ សិទ្ធិរបស់ ជនរងគ្រោះត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី (...)។

៤. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានសង្កេតឃើញថា លទ្ធភាពចូលរួមតាមផ្លូវច្បាប់របស់ដើមបណ្តឹង រដ្ឋប្បវេណីត្រូវបានដាក់កំហិតជាបន្តបន្ទាប់ ។ ចាប់តាំងពីមានការសម្រេចទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី ឱ្យចូលរួមក្នុងនីតិវិធីសវនាការក្នុងអង្គបុរេនៅខែកុម្ភៈ ឆ្នាំ ២០០៨ មក ការដាក់កំហិតជាច្រើន ជាក់ស្តែងតាមផ្លូវច្បាប់ ដោយផ្ទាល់ក្តី និង ដោយប្រយោលក្តីបាននាំឱ្យមានការរើសអើងប្រឆាំងនឹងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលប៉ះពាល់ដល់ការចូលរួមក្នុងដំណាក់កាលនីតិវិធីដូចបានចែងក្នុងច្បាប់នានាដែលពាក់ព័ន្ធ។

៥. ហេតុការណ៍នៃការរើសអើងចុងក្រោយ និង ធ្ងន់ធ្ងរបំផុតគឺការចេញ “សេចក្តីណែនាំស្តីពីការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីនាពេលសវនការ នៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន”។ សេចក្តីណែនាំនេះចុះហត្ថលេខាដោយប្រធានអង្គបុរេជំនុំជម្រះ ក្នុងនាមអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៨ ។ សេចក្តីណែនាំនេះបានដាក់កំរិតនូវសិទ្ធិចូលរួមក្នុងដំណើការនីតិវិធី ក្នុងមធ្យោបាយ មួយដែលអាចទទួលយកបាន (សូមប្រៀបធៀបជាមួយចំនុច II)។

៦. ការរើសអើងលើសពីនេះ បណ្តាលមកពីវិធានការជាក់ស្តែងសំរាប់ដំណើរការនីតិវិធីរឿងក្តី ៖

ក. វិសោធនកម្មនៃសេចក្តីណែនាំអនុវត្តបច្ចុប្បន្ន[7] តំរូវឱ្យគ្រប់ភាគីមានកាតព្វកិច្ចដាក់ ជូននូវឯកសារ នានាជាភាសាខ្មែរ និងភាសាមួយទៀតដែលប្រើប្រាស់ក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានជះឥទ្ធិពលដ៏តានតឹង លើដើមបណ្តឹងរដ្ឋប្បវេណីណា ដែលគ្មានមូលនិធិ ឬធនធាន សំរាប់បកប្រែឯកសារ។

ខ. ឥទ្ធិពលនេះកាន់តែមានលក្ខណៈតានតឹងឡើងពេលមានកាលកំណត់ឈប់ទទួលពាក្យដែលមាន គោលបំណងសំដៅកាត់បន្ថយពេលវេលាដែលបានអនុញ្ញាតិឱ្យកាន់តែខ្លី។

គ. ម៉្យាងទៀត ការរើសអើងចំពោះដើមបណ្តឹងរដ្ឋប្បវេណី ក៏បណ្តាលមកពីការសំរេចអារកាត់ដោយលំអៀងចំពោះពេលវេលាសំរាប់ភាគីនានាក្នុងការធ្វើការសន្និដ្ឋានផ្ទាល់មាត់ក្នុងសវនាការជំនុំជម្រះឧទ្ធរណ៍ (សូមប្រៀបធៀបជា មួយចំនុច III)។

៧. សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីធ្វើការសង្កេតជាទូទៅចំពោះឥទ្ធិពល នៃការរើសអើងទាំងនេះដែលជាមូលហេតុត្រូវព្រួយបារម្ភ ហើយពួកគេស្នើសុំឱ្យអង្គបុរេជំនុំជម្រះគោរពដល់សិទ្ធិទាំងស្រុងរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមដំណាក់កាលនីតិវិធី។

## II. ផលប៉ះពាល់នៃការរើសអើងដែលស្តែងចេញពីការណែនាំរបស់អង្គបុរេជំនុំជម្រះឱ្យដើមបណ្តឹងរដ្ឋប្បវេណីចូលខ្លួនថ្លែងអឡិករណ៍ផ្ទាល់មាត់

៨. នៅថ្ងៃទី២០ ខែឧសភា ២០០៨ ប្រធានអង្គបុរេជំនុំជម្រះបានណែនាំថា "រាល់ការធ្វើសេចក្តីសន្និដ្ឋាន តាងនាមឱ្យដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធានទី៧៧ (១០) ត្រូវធ្វើឡើងដោយមេធាវីរបស់ដើមបណ្តឹង រដ្ឋប្បវេណី"[8] ។ អង្គបុរេជំនុំជំរះយល់ឃើញថាការណែនាំនេះធ្វើឡើងក្នុងគោលបំណង "ដើម្បីធានាផលប្រយោជន៍ ឱ្យនីតិវិធីប្រព្រឹត្តទៅយ៉ាងឆាប់រហ័ស និង មានការដាក់សារណាសមស្រប

---

7 ចំណាត់ការនីតិវិធីនៃអង្គជំនុំជំរះវិសាមញ្ញនៃតុលាការកម្ពុជា (ខែមករា២០០៧) ត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី ២៩ មេសា ២០០៨ ។

8 សំណុំរឿងក្តីលេខ០០២ /១៩ កញ្ញា ២០០៧- អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា-ការិយាល័យសហចៅក្រមស៊ើប អង្កេត (អង្គបុរេជំនុំជម្រះ០២)សេចក្តីណែនាំ ឱ្យដើមបណ្តឹងរដ្ឋប្បវេណីចូលខ្លួនធ្វើការសន្និដ្ឋានផ្ទាល់មាត់ក្នុង អំឡុងពេលសវនាការជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន (២០ឧសភា២០០៨) ERN00១៨៩៤៥៩-00១៨៩៤៦0 ឯកសារលេខ C២0/I/២១ ។

ហើយយឿសវាងការបង្អាក់ ដល់ការ ជំនុំជម្រះ។"[9] ម៉្យាងទៀត "(...) អង្គបុរេជំនុំជំរះកត់សំគាល់ឃើញពីការកើនឡើងនូវបរិមាណ នៃដើមបណ្តឹងរដ្ឋប្បវេណី និងឋានៈខុសៗគ្នារបស់ពួកគេ ។ លើសពីនេះ អង្គបុរេជំនុំជម្រះបាន លើកមកពិចារណានូវចរិតបច្ចេកទេស នៃសេចក្តីថ្លែងសារណារបស់ភាគីទាំងអស់ រួមទាំងដើមបណ្តឹងរដ្ឋប្ប វេណីក្នុងបណ្តឹងឧទ្ធរណ៍នេះផងដែរ"[10]។

៩. ជាក់ស្តែង ប្រធានអង្គបុរេជំនុំជម្រមោះនការភ័ន្តច្រឡំក្នុងអង្គហេតុទាក់ទងនឹងដំណើរការរឿង ក្តីនៃសំណុំរឿងលេខ ២[11]។ មានដើមបណ្តឹងរដ្ឋប្បវេណីតែ៣នាក់បន្ថែមទៀតតែប៉ុណ្ណោះចាប់តាំងពីថ្ងៃទី ២៣ ខែ មេសា ២០០៨ ប៉ុន្តែកន្លងមកពួកគេទាំងនោះមិនមានតំណាងការពារក្តីតាមផ្លូវច្បាប់នោះទេ ។ ពួកគេមិនបានទទួល ដំណឹងពីសវនាការ ជំនុំជម្រលើះបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះ អាសន្ននោះទេ។ ម៉្យាងទៀត នៅមានភាពខុសគ្នាមួយចំនួនដែលអាចវិនិច្ឆ័យបាន នៅក្នុងឋានៈរបស់ដើម បណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងនីតិវិធី ហើយអាចត្រូវបានសង្កេតតាមរយៈការពិតដែលថា គ្រប់សេចក្តីសន្និដ្ឋាន ជាលាយលក្ខណ៍អក្សរ ទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានធ្វើឡើងជាសេចក្តីសន្និដ្ឋានរួម។

១០. លើសពីនេះទៀត សេចក្តីណែនាំ នោះមិនអាចត្រូវបានគេចាត់ទុកថាជាវិធានការ សមស្របដើម្បី ធានាឱ្យនីតិវិធីដំណើរការបានឆាប់រហ័សនោះទេ ។ នីតិវិធីដែលមានប្រសិទ្ធភាពនិងឆាប់រហ័ស ត្រូវបានធានារួចរាល់ ហើយដោយពេលវេលាកំណត់សំរាប់ ធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ក្នុងអំឡុងពេលសវនាការ។

---

9 សំណុំរឿងក្តីលេខ០០២ /១៩ កញ្ញា ២០០៧- អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា-ការិយាល័យសហចៅក្រមស៊ើប អង្កេត (អង្គបុរេជំនុំជម្រះ០២)សេចក្តីណែនាំ ឱ្យដើមបណ្តឹងរដ្ឋប្បវេណីចូលខ្លួនថ្លែង ទឡ្ហីករណ៍ផ្ទាល់មាត់ក្នុង អំឡុងពេលសវនាការជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន (២០ឧសភា២០០៨) ERN០០១៨ ៩៤៥៩-០០១៨៩៤៦០ ឯកសារលេខ C២០/I/២១។

10 សំណុំរឿងក្តីលេខ០០២ /១៩ កញ្ញា ២០០៧- អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា-ការិយាល័យសហចៅក្រមស៊ើប អង្កេត (អង្គបុរេជំនុំជម្រះ០២)សេចក្តីណែនាំ ឱ្យដើមបណ្តឹងរដ្ឋប្បវេណីចូលខ្លួន ធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ក្នុងអំឡុងពេល សវនាការជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន (២០ឧសភា២០០៨) ERN០០១៨ ៩៤៥៩-០០១៨៩៤៦០ ឯកសារលេខ C២០/I/២១។

11 សំណុំរឿងក្តីលេខ០០២ /១៩ កញ្ញា ២០០៧- អង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា-ការិយាល័យសហចៅក្រមស៊ើបអង្កេត

១១. ទស្សនៈមួយក្នុងចំណោមទស្សនៈសំខាន់ៗទាំងអស់នៃសេចក្តីណែនាំ សំរាប់ហាមឃាត់ បានណែនាំសេចក្តីសន្និដ្ឋានការផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលតំណាងដោយមេធាវី អាស្រ័យជាចំបងទៅ លើការបកស្រាយតាមវិធាន ៧៧(៤) និង (១០)នៃ វិធានផ្ទៃក្នុង ។ ចំណែកឯវាក្យខ័ណ្ឌ៤បានអះអាងថា "សហមេធាវីរបស់ភាគីអាចសុំមើលសំណុំរឿងរហូតដល់ថ្ងៃសវនាការ" រីឯវាក្យខ័ណ្ឌ១០ បានលើកឡើងថា "បន្ទាប់ពីសហចៅក្រមរបាយការណ៍បានអានរាយការណ៍ សហព្រះរាជអាជ្ញា និង មេធាវីរបស់ភាគី អាចធ្វើសេចក្តីសន្និដ្ឋាន របស់ខ្លួនដោយសង្ខេប។"

១២. ប្រធានអង្គបុរេជំនុំជំរះបកស្រាយថានោះគឺជាវិធានផ្សេងដោយឡែកមួយដែលគ្រាន់តែផ្តល់សិទ្ធិ អំណាចដល់មេធាវីក្នុងការបំពេញសកម្មភាពដូចបានពោលកន្លងមកតែប៉ុណ្ណោះ ។ ទោះយ៉ាងណាក្តី ទស្សនៈបែបនេះ ត្រូវបានមជ្ឈដ្ឋានទូទៅមើលឃើញថាខុសនៅពេលដែលគេក្រឡេកមើលមុខងារដែលមេធាវី ត្រូវបំពេញតាងនាម ឱ្យដើមបណ្តឹងរដ្ឋប្បវេណី ។ ដោយហេតុថាពុំមានលក្ខខណ្ឌតំរូវឱ្យពួកគេជ្រើសរើសតំណាង ទើបបានជាបណ្តឹងនិមួយៗ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ពួកគេក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី អាចអនុវត្តទៅបានជាលក្ខណៈបុគ្គល[12]។ ចំណុចនេះក៏ត្រូវបានទទួលស្គាល់ដោយប្រធានអង្គបុរេជំនុំជម្រះ ខណៈដែលលោកដាក់កំរិត ការណែនាំឱ្យភាគី ដែលបានជ្រើសរើសតំណាងផ្លូវច្បាប់របស់ខ្លួនហើយ។

១៣. បន្ថែមលើសពីនេះទៅទៀត ការដាក់កំហិតបែបនេះមានវិសមិតភាពទៅនឹងទស្សនៈស្តីអំពីតំណាង តាមផ្លូវច្បាប់។ការតំណាងតាមផ្លូវច្បាប់មានន័យថាជាការជួយទ្រទ្រង់ឱ្យប្រសើរឡើង ដល់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងដំណើរការនីតិវិធីនៃរឿងក្តី ។ សហមេធាវីត្រូវជួយដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងពីផល ប្រយោជន៍សំខាន់ៗ របស់ពួកគេក្នុងទំរង់សមស្របនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សេចក្តីណែនាំរបស់ប្រធាន អង្គបុរេជំនុំជម្រះបានបង្កើតនូវភាពចំរូងចំរាស់មួយដល់ដើមបណ្តឹងរដ្ឋប្បវេណី ។ ម៉្យាង ពួកគេមើលឃើញពីតំរូវ យោបល់វិជ្ជាជីវៈផ្នែកច្បាប់ពីមេធាវីណាម្នាក់ ។ ឯម៉្យាងវិញទៀត ពួកគេមានទស្សនៈយល់ឃើញថា ការចូលរួម ចំណែក និង វិភាគទានជាលក្ខណៈបុគ្គលនាំឱ្យមានសារៈប្រយោជន៍ និង ចាំបាច់។

ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះឈប់ធ្វើជាតំណាងតាមផ្លូវច្បាប់ឱ្យពួកគេដោយសារតែការពិចារណាទាំងនេះ នោះវារឹតតែមានការលំបាកឡើងក្នុងការពង្រឹងជំហររបស់ពួកគេក្នុងដំណើរការនីតិវិធីរឿង ក្តីបន្តទៅ ថ្ងៃមុខទៀត ។

---

12 មានតែសិទ្ធិតាមដានសំណុំរឿងទេដែលអាចត្រូវបានកំហិតលក្ខ័ណ្ឌមួយចំនួន

១៤. សេចក្ដីសំអាងមួយផ្សេងទៀតដែលផ្ដល់ដោយប្រធានអង្គបុរេជំនុំជម្រះ (ដែលគេគិតថាជា "ចំណុចត្រូវពិចារណាដ៏សំខាន់មួយ"[13]) គឺបានប្រកាសថា ការដាក់កំហិតអំពីសេចក្ដីសន្និដ្ឋានផ្ទាល់មាត់មានសារៈសំខាន់ ដើម្បីធានាឱ្យមាននូវគោលការណ៍ជំនុំជម្រះក្ដីដោយយុត្តិធម៌ ។ ប្រធានអង្គបុរេជំនុំជម្រះអះអាងថា "មេធាវីការពារគួរ ដឹងអំពីខ្លឹមសារនៃសេចក្ដីថ្លែងទឡ្ហីករណ៍ផ្ទាល់មាត់ របស់ដើមបណ្ដឹងរដ្ឋប្បវេណីមុននឹងសវនាការ"[14]។

១៥. ទោះយ៉ាងណាក៏ដោយ ការអះអាងបែបនេះជាការព្រងើយកន្ដើយចំពោះការពិតដែលថា វិធានផ្ទៃក្នុង បានកំណត់រួចទៅហើយនូវសេចក្ដីសន្និដ្ឋានផ្ទាល់មាត់អំពីបញ្ហាអង្គហេតុ និងអង្គច្បាប់ ដែលបានចង្អុលបង្ហាញក្នុង សារណាបណ្ដឹងឧទ្ធរណ៍។ វិធាន៧៥ (៤) នៃវិធានផ្ទៃក្នុងចែងថា ៖

"ការដាក់សារណាបណ្ដឹងឧទ្ធរណ៍ ត្រូវមានបញ្ជាក់អំពីអំណះអំណាងខាងអង្គហេតុនិងអង្គច្បាប់ដែលជា មូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍ ដោយមានភ្ជាប់មកជាមួយនូវឯកសារសំអាងទាំងនោះ។ ម្ចាស់បណ្ដឹងឧទ្ធរណ៍ មិនអាចេ លើកក្នុងពេលសវនាការ បញ្ហាអង្គហេតុឬ អង្គច្បាប់ដែលមិនមានចែងនៅក្នុងសារណាបណ្ដឹងឧទ្ធរណ៍ ឡើយ។"[15]

មកទល់ពេលនេះ គ្មានទំនាស់ក្នុងការបកស្រាយវិធាន៧៥ (៤) នៃវិធានផ្ទៃក្នុងទេ សារណាទាំងអស់របស់គូភាគីត្រូវបានកំហិតចំពោះបញ្ហាអង្គហេតុនិងអង្គច្បាប់ដែលម្ចាស់បណ្ដឹងឧទ្ធរណ៍បានលើកឡើងក្នុងសារណា ឧទ្ធរណ៍របស់គាត់ ។ ដូច្នេះ វិសាលភាពនៃអំណះអំណាងដែលអាចត្រូវបានលើកឡើងក្នុងសវនាការ មានលក្ខណៈ អាចទស្សន៍ទាយបានសំរាប់មេធាវីការពារ។

គោលបំណងនៃវិធាន៧៥ (៤) នៃវិធានផ្ទៃក្នុង គឺជំរុះចេញនូវសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ដែលមិនសមហេតុផលមិនឱ្យបង្ហាញជូននៅក្នុងសវនាការ។ លើសពីនេះទៅទៀត បទដ្ឋាននេះតម្រូវឱ្យភាគីចូលរួម

---

13 សំណុំរឿងក្ដីលេខ០០២ /១៩ កញ្ញា ២០០៧- អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា-ការិយាល័យសហចៅក្រមស៊ើបអង្កេត (អង្គបុរេជំនុំជម្រះ០២)សេចក្ដីណែនាំ ឱ្យដើមបណ្ដឹងរដ្ឋប្បវេណីចូលខ្លួនថ្លែង ទឡ្ហីករណ៍ផ្ទាល់មាត់ក្នុងអំឡុងពេលសវនាការជំនុំជំរះលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន (២០ឧសភា២០០៨) ERN០០១៨ ៩៤៥៩-០០១៨៩៤៦០ ឯកសារលេខ C២០/I/២១។

14 សំណុំរឿងក្ដីលេខ០០២ /១៩ កញ្ញា ២០០៧- អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា-ការិយាល័យសហចៅក្រមស៊ើប អង្កេត (អង្គបុរេជំនុំជម្រះ០២)សេចក្ដីណែនាំ ឱ្យដើមបណ្ដឹងរដ្ឋប្បវេណីចូលខ្លួនថ្លែង ទឡ្ហីករណ៍ផ្ទាល់មាត់ក្នុងអំឡុងពេលសវនាការ ជំនុំជំរះលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន (២០ឧសភា២០០៨) ERN០០១៨ ៩៤៥៩-០០១៨៩៤៦០ ឯកសារលេខ C២០/I/២១។

15 ការសង្កត់ន័យត្រូវបានបន្ថែម

ទាំងអស់ រៀបចំសំអាងរបស់ពួកគេឱ្យមានប្រសិទ្ធភាព ដោយប្រមើលស្មានទុកជាមុនអំពីទឡ្ហីករណ៍ដែលភាគីម្ខាងទៀតនឹង លើកឡើងក្នុងសេចក្តីសន្និដ្ឋានរបស់ពួកគេ។ ទោះបីជាយ៉ាងណាក៏ដោយនេះមិនមានន័យថា អំណះអំណាងទាំងអស់ សុទ្ធតែពិស្តារហើយចាំបាច់មាននៅក្នុងសារណាជាលាយលក្ខណ៍អក្សរនោះទេ ។ គោលបំណង នៃសំអាងផ្ទាល់មាត់ គួរតែផ្តោះបញ្ចាំងពង្រឹង និងបង្រួមចូលគ្នានូវទឡ្ហីករណ៍នានាដែលចែងក្នុង សារណាជាលាយលក្ខណ៍អក្សរ ។ ទាំងនេះ អនុញ្ញាតិសំរាប់ការលើកឡើងនូវទិដ្ឋភាពថ្មីៗ ដរាបណាវាទាក់ទងនឹងអំណះអំណាងនោះ ហើយដរាបណាវាយោងទៅ អង្គហេតុនិងអង្គច្បាប់ដែលបានសរសេរក្នុងសារណារបស់ ដើមបណ្តឹងឧទ្ធរណ៍ ។ ទោះបីជាដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីរបស់ពួកគេផ្តល់ការអំអាងផ្ទាល់មាត់ តែមួយក៏ដោយ ពួកគេត្រូវបានដាក់កំរិតដោយព្រំដែន អង្គហេតុ និងអង្គច្បាប់នៃសារណាក្នុងបណ្តឹងឧទ្ធរណ៍ ។

ការទទួលយកនូវទឡ្ហីករណ៍របស់ប្រធានអង្គបុរេជំនុំជំរះ មានន័យថាសេចក្តីសំអាងណាដែលមិនបានចែង ក្នុងសារណាជាលាយលក្ខណ៍អក្សរ មិនអាចត្រូវបានបង្ហាញជូននៅក្នុងសវនាការនោះទេ។ ការពិត វាគួរមានន័យថា សវនាការជំនុំជំរះ នឹងត្រូវបន្ថយមកជា សវនាការអាន សារណាជាលាយលក្ខណ៍អក្សរជា សាធារណៈ។ លទ្ធផលបែប នេះមិនបានចែងដោយច្បាប់នានាដែលពាក់ព័ន្ធទេ ហើយក៏មិនមែនត្រូវសំរាប់ការ ការពារផ្លូវច្បាប់ដ៏មានប្រសិទ្ធភាព នោះដែរ ។

ជាចុងបញ្ចប់ ទឡ្ហីករណ៍នេះថែមទាំងមិនបានគាំទ្រការដកចេញនូវសំអាងផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនបានការពារដោយមេធាវីតំណាងណាមួយនោះទេ។ មិនមានភាពខុសគ្នាអ្វីទេ ប្រសិន បើមេធាវីការពារ ត្រូវប្រឈមមុខជាមួយសេចក្តីសន្និដ្ឋានផ្ទាល់មាត់ដោយមេធាវីណាមួយ ឬ ដោយដើមបណ្តឹងរដ្ឋប្បវេណីផ្ទាល់ ។ ក្នុងករណីទាំងពីរនេះវាអាចដែលថាទឡ្ហីករណ៍នឹងត្រូវបានបង្ហាញជូនក្នុងពេលសវនាការ ដែលការពិតទឡ្ហីករណ៍ ទាំងនោះមាន ចែងនៅក្នុងអង្គហេតុនិងអង្គច្បាប់នៃសារណាក្នុងបណ្តឹងឧទ្ធរណ៍ ហើយគ្រាន់តែមិនទាន់ឱ្យមេធាវី ការពារបានដឹង។

១៦. ប្រធានអង្គបុរេជំនុំជម្រះប៉ាន់ស្មានតំលៃដោយខុស ចំពោះសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ដើមបណ្តឹង រដ្ឋប្បវេណីដែលអាចមាន នេះបើផ្អែកលើមូលដ្ឋានពិតប្រាកដនៃការសំរេចចិត្តក្នុងសវនាការថ្មីៗនេះក៏ដូចជាការទទួល យកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងសង្គមកម្ពុជា ។ ប្រធានអង្គបុរេជំនុំជម្រះចាត់ទុកសេចក្តីសន្និដ្ឋាន ផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជាការរួមចំណែកដែលមិនចាំបាច់ នៅ

ពេលធ្វើការសំរេចចិត្តលើបណ្តឹង ឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នលើអៀងធីរិទ្ធ ។ លោកប្រធាន បានអះអាងថា សេចក្តីសន្និដ្ឋាន ដែលធ្វើឡើងដោយភាគីមាន "ចរិតលក្ខណៈបច្ចេកទេស"[16]។

ទោះយ៉ាងណា ដោយសារគោលបំណងនៃសវនាការគឺការសំរេចលើដីកាឃុំខ្លួនបណ្តោះអាសន្ន ច្បាប់ ដែលពាក់ព័ន្ធគឺវិធាន៦៣ វាក្យខ័ណ្ឌទី៣(ខ) នៃវិធានផ្ទៃក្នុង។ បទដ្ឋាននេះចែងថា ៖

*"(ខ)* សហចៅក្រមស៊ើបអង្កេតយល់ឃើញថាការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការដ៏ចាំបាច់ ដើម្បី ៖ *(...)*

> ១)រារាំងកុំឱ្យជនដែលត្រូវចោទនោះគៀបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទនិងអ្នកសមគំនិត ចំពោះបទឧក្រិដ្ឋដែលស្ថិត នៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះសាមញ្ញ។*(...)"*

ការសំរេចលើបញ្ហាថាតើមានគ្រោះថ្នាក់នៃការដាក់សម្ពាធលើសាក្សីនានាឬអត់ មិនមែនជាបញ្ហាបច្ចេកទេសទាល់តែសោះ។ សាក្សីនិងជនរងគ្រោះអាចប្រាប់យ៉ាងលំអិតអំពីថា "តើគេអាចដាក់សម្ពាធតាមវិធីណា" ហើយពួកគេមានអារម្មណ៍ភ័យខ្លាចបែបណាចំពោះ"ការប្រព្រឹត្តល្មើសច្បាប់" ។ ជាការពិតបញ្ហានេះ (ប្រសិនបើ លក្ខខណ្ឌក្នុងវិធាន ៦៣(៣)(ខ)នៃវិធានផ្ទៃក្នុងត្រូវបានបំពេញ)ក៏ពឹងផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួនរបស់សាក្សីផងដែរ ហើយជាលទ្ធផលទស្សនៈផ្ទាល់ខ្លួនទាំងនេះគួរត្រូវបានយកមកពិចារណា។ ភាពពិត ជាក់ស្តែងនៃភាសា និយាយរបស់ពួកគេមិនអាចត្រូវបានជំនួសដោយអ្នកតំណាងស្របច្បាប់របស់ពួកគេនោះទេ ។

តាមធម្មតា អន្តរាគមន៍ផ្ទាល់ខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវបានសំរបសំរួលនិងប្រតិបត្តិក្នុងអំឡុងពេលកំណត់ដោយអង្គបុរេជំនុំជំរះ។

ម៉្យាងទៀត ការចូលរួមយ៉ាងសកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសវនាការគឺជាការរួមចំណែកដ៏មានតំលៃ សំរាប់ដំណើរការលើកទឹកចិត្តឱ្យមានការចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងចំណោម

---

16 សំណុំរឿងក្តីលេខ00២ /១៩ កញ្ញា ២00៧- អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា-ការិយាល័យសហចៅក្រមស៊ើប អង្កេត (អង្គបុរេជំនុំជម្រះ0២)សេចក្តីណែនាំ ឱ្យដើមបណ្តឹងរដ្ឋប្បវេណីចូលខ្លួនផ្ទៃង ទឡ្ហីករណ៍ផ្ទាល់មាត់ក្នុងអំឡុងពេលសវនាការជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន (២0ឧសភា២00៨) ERN00១៨ ៩៤៥៩-00១៨៩៤៦0 ឯកសារលេខ C២0/I/២១។

ប្រជាជនកម្ពុជាទាំងអស់ (មិនមែនត្រឹមតែនៅចំពោះមុខអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជានោះទេ) ហើយក៏ អាចជួយអន្ទងចិត្តអ្នក ដទៃទៀតឱ្យដាក់ពាក្យប្តឹងក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។

១៧. បន្ថែមពីនេះ ការចូលរួមយ៉ាងសកម្មរបស់ជនរងគ្រោះ គឺជាទិដ្ឋភាពនៃដំណើរការនីតិវិធី ព្រហ្មទណ្ឌ ដែលនឹងមានការយកចិត្តទុកដាក់តាមដានកាន់តែច្រើនឡើងៗពីអន្តរជាតិ។

ក្រុមប្រឹក្សាសហភាពអឺរ៉ុបបានគូសបញ្ជាក់ពីសារៈប្រយោជន៍ នៃការចូលរួមរបស់ជនរងគ្រោះ នៅក្នុង "សេចក្តីសំរេចគំរោងការក្រុមប្រឹក្សា នៅថ្ងៃទី១៥មីនា២០០១ ស្តីអំពី ឋានៈរបស់ជនរងគ្រោះក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ"។ មាត្រា ៣ នៃសេចក្តីសំរេចគំរោងការនេះចែងថា ៖

"រដ្ឋជាសមាជិកនិមួយៗ ត្រូវការពារលទ្ធភាពសំរាប់ជនរងគ្រោះឱ្យចូលរួមឆ្លើយក្នុងអំឡុងពេលដំណើការរឿងក្តីនិងផ្តល់ភស្តុតាង"[17] ។ បញ្ញត្តិនេះទាមទាឱ្យផ្តល់ការអនុញ្ញាតដល់ជនរងគ្រោះ ដើម្បីសំដែងទស្សនៈ ដោយខ្លួនឯង។

១៨. សេចក្តីបង្គាប់បញ្ជាភ្លាមៗក៏មិនត្រូវបានគ្របដណ្តប់ដោយសិទ្ធិអំណាចរបស់ប្រធានអង្គបុរេជំនុំ ជម្រះ ដែលបានចេញសេចក្តីណែនាំដោយតាងនាមខ្លួនលោកផ្ទាល់ ។ សិទ្ធិអំណាចរបស់ប្រធានអង្គបុរេ ត្រូវបានចែងនៅ ក្នុងវាក្យខ័ណ្ឌមួយចំនួនក្នុងវិធាន៧៧ នៃវិធានផ្ទៃក្នុង។ វាក្យខ័ណ្ឌ៣នៃវិធាននេះតំរូវឱ្យប្រធាន អង្គបុរេជំនុំជំរះ "បញ្ជាក់ឱ្យច្បាស់ថាសំណុំរឿងមានលក្ខណៈទាន់ហេតុការណ៍ ហើយកំណត់កាលបរិច្ឆេទសំរាប់សវនាការ"។ វាក្យខ័ណ្ឌ៨កំណត់លើការសំរេចចិត្តរបស់ប្រធានអង្គបុរេជំនុំជំរះឱ្យចាត់តាំងចៅក្រមបំរុង មួយរូបជំនួសចៅក្រម ពេញសិទ្ធិដែលអវត្តមាន ។ ចំណែកឯវាក្យខណ្ឌ ៩ ចែងពីការតែងតាំងសហចៅក្រមរបាយការណ៍ ។

សិទ្ធិអំណាចដែលបានរៀបរាប់ខាងលើនេះគឺជាចរិតនិងកង្វល់ដូចគ្នានៃការចាត់ចែងឱ្យមានសវនាការផ្លូវការ និងតួនាទីដឹកនាំរបស់ ប្រធានអង្គបុរេជំនុំជំរះ។ ដូច្នេះ សេចក្តីណែនាំទាំងឡាយដែលដាក់កំហិតលើ សិទ្ធិចូលរួមក្នុង នីតិវិធីត្រូវតែស្ថិតក្នុងសិទ្ធិអំណាចរបស់អង្គជំនុំជំរះទាំងមូល។

១៩. ជាចុងបញ្ចប់ សេចក្តីណែនាំត្រូវបានគេយល់ថាជាការបំពានសិទ្ធិបញ្ញត្តមូលដ្ឋានដែលត្រូវបានតំរូវដោយគោលការណ៍ទូទៅនៃនីតិវិធី ។ ប្រសិនបើដីកា សេចក្តីណែនាំ ឬសេចក្តីសំរេចណាមួយប៉ះពាល់ ដល់ស្ថានភាព នីតិវិធី និង សិទ្ធិរបស់ភាគី ត្រូវជូនដំណឹងជាមុនដល់ភាគីមុននឹងចេញសេចក្តីសំរេច (ហើយកាន់

---

[17] សេចក្តីសំរេចគំរោងការក្រុមប្រឹក្សា នៅថ្ងៃទី១៥មីនា២០០១ ស្តីអំពី ឋានៈរបស់ជនរងគ្រោះក្នុងនីតិវិធីព្រហ្មទណ្ឌ (២០០១ /២២០ /JHA) L៨២ /២

តែចាំបាច់ ជាងនេះទៅទៀត ប្រសិនបើការសំរេចនោះជាការសំរេចបិទផ្លូវតវ៉ា)។ ផ្ទុយទៅវិញ ប្រធានអង្គបុរេជំនុំជម្រះ បានចេញសេចក្តីណែនាំរបស់លោកភ្លាមៗនៅមុនពេលបើកសវនាការ ដោយមិនបានស្តាប់យោបល់ ពីដើមបណ្តឹង រដ្ឋប្បវេណីទេ ។ ដោយហេតុតែសេចក្តីណែនាំនេះធ្វើឡើងយ៉ាងបញ្ជាប់ប្រញាល់គួរឱ្យភ្ញាក់ផ្អើល ហើយប៉ះពាល់ ធ្ងន់ធ្ងរដល់សិទ្ធិចូលរួមក្នុងដំណើរការនីតិវិធីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ គេយល់ថាសេចក្តីណែនាំនេះរំលោភ យ៉ាងអយុត្តិធម៌លើគោលការណ៍នីតិវិធី ។

## III. ភាពចាំបាច់នៃការការពារផ្លូវច្បាប់ទល់នឹងសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះ

២០. ជាទូទៅ បទបញ្ជាផ្ទៃក្នុងទទួលស្គាល់ ភាពចាំបាច់នៃការការពារតាមផ្លូវច្បាប់ក្នុងអំឡុងពេលដំណើរការ នីតិវិធីនៅអង្គបុរេជំនុំជម្រះ[18] ហើយធានាឱ្យមានការប្តឹងឧទ្ធរណ៍ទល់នឹងសេចក្តីសំរេចណាមួយរបស់ សហចៅក្រម ស៊ើបអង្កេត។

ទោះជាយ៉ាងណាក៏ដោយ ការរំលោភលើសិទ្ធិចូលរួមក្នុងនីតិវិធីរបស់ដើមបណ្តឹងរដ្ឋប្បវេណី បង្កឡើង ដោយសេចក្តីណែនាំរបស់ប្រធានអង្គបុរេជំនុំជំរះទាក់ទងនឹងសេចក្តីសំរេចចិត្តមួយ ដែលមិនធ្លាប់ធ្វើឡើង ដោយសហ ចៅក្រមស៊ើបអង្កេតនោះទេ ។ វិធានផ្ទៃក្នុង ឬក្រមនីតិវិធីព្រហ្មទណ្ឌមិនបានចែងអំពីការការពារតាមផ្លូវច្បាប់ ប្រឆាំងនឹងការចេញសេចក្តីណែនាំបែបនោះទេ។

គោលការណ៍នៃការការពារតាមផ្លូវច្បាប់ដ៏មានប្រសិទ្ធភាពនេះ បញ្ជាក់ថាមធ្យោបាយផ្លូវច្បាប់ប្រឆាំងនឹងការរំលោភសិទ្ធិរបស់ភាគីត្រូវតែបានផ្តល់ឱ្យ ប្រសិនបើអង្គបុរេជំនុំជំរះរំលោភបំពានលើសិទ្ធិរបស់ ពួកគេ។

២១. ទស្សនៈស្តីអំពីការការពារតាមផ្លូវច្បាប់ដ៏មានប្រសិទ្ធភាពនេះគឺជាគោលការណ៍មូលដ្ឋានមួយដែលតំរូវ ឱ្យមានក្នុងនីតិរដ្ឋ ។

(ក) រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ គោរពយ៉ាងខ្ពង់ខ្ពស់ដល់គោលការណ៍នេះ។ ជាក់ស្តែង មាត្រា ៣៩ ចែងថា ៖

---

18 វិធានទី៧១ និង៧២នៃវិធានផ្ទៃក្នុងចែងទាក់ទងនឹងការដកសេចក្តីមិនយល់ព្រមក្នុងចំណោមសហចៅក្រមស៊ើបអង្កេត និង សហព្រះរាជអាជ្ញា ដោយអង្គបុរេជំនុំជំរះ។ លើសពីនេះទៅទៀតការការពារតាមផ្លូវច្បាប់មានចែងនៅក្នុង វិ ធាន៧៤ នៃវិធានផ្ទៃក្នុង។ វាក្យខ័ណ្ឌ៤នៃបទដ្ឋាននេះផ្តល់សិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការប្តឹងឧទ្ធរណ៍តាមផ្លូវច្បាប់ ប្រឆាំងនឹងសេចក្តីសំរេចរបស់សហចៅក្រមស៊ើបអង្កេត។បណ្តឹងឧទ្ធរណ៍ទាំងនោះនឹងត្រូវសំរេចដោយអង្គបុរេជំនុំជម្រះ។

00195898



ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូតខាត ដែលបណ្តាលមក ពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គ ការទាំងនោះ។ ការដោះស្រាយ បណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។

រីឯមាត្រា១២៨(ថ្មី)ចែងថា ៖

"អំណាចតុលាការធានារក្សាអណាគតិ និងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ។"

មាត្រាទាំងនេះបញ្ជាក់យ៉ាងច្បាស់ថាដាច់ខាតត្រូវតែមានលទ្ធភាពអាចប្តឹងឧទ្ធរណ៍តាមផ្លូវច្បាប់ ប្រសិនបើ ការរំលោភលើសិទ្ធិបំរុងនឹងកើតឡើង។

(ខ) តំរូវការនេះក៏មានចែងផងដែរក្នុងមាត្រា៦នៃ អនុសញ្ញាទ្វីបអឺរ៉ុបដើម្បីការពារសិទ្ធិមនុស្សនិង សេរីភាពជាមូលដ្ឋាន[19] ៖

"ដើម្បីបញ្ជាក់ពីសិទ្ធិពលរដ្ឋនិងកាតព្វកិច្ចរបស់ខ្លួន ឬដើម្បីសំរេចចំពោះការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌម្តុកលើខ្លួន បុគ្គលម្នាក់ៗមានសិទ្ធិទទួលបានការជំរះក្តីមួយដោយយុត្តិធម៌និងជាសាធារណៈ ក្នុងអំឡុងពេលវេលាសមហេតុផលមួយ ដោយអង្គជំនុំជម្រះមួយដែលឯករាជ្យនិងមិនលំអៀង ដែលបង្កើត ឡើងដោយច្បាប់។"

(គ) តំរូវការចំពោះការការពារតាមផ្លូវច្បាប់ដ៏មានប្រសិទ្ធភាព ទល់នឹងសេចក្តីណែនាំរបស់ អង្គបុរេជំនុំជម្រះក៏អាចត្រូវបានគេមើលឃើញផងដែរក្នុងលក្ខន្តិកៈក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ មាត្រា៣៤ វាក្យខណ្ឌទី២នៃលក្ខន្តិកៈក្រុងរ៉ូមសន្មត់ពីការបង្កើតផ្នែកសាលាឧទ្ធរណ៍ដែលទទួលខុសត្រូវចំពោះ បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីការបស់អង្គបុរេជំនុំជម្រះ[20] ។ ជាក់ស្តែងលក្ខន្តិកៈក្រុងរ៉ូមមិនបានចែង ពីបណ្តឹង ឧទ្ធរណ៍របស់ដើម បណ្តឹងរដ្ឋប្បវេណីទេ ព្រោះគ្មានដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការក្តី នៅមុខតុលាការ ព្រហ្មទណ្ឌអន្តរជាតិ ឡើយ។

ទោះយ៉ាងនេះក្តី នេះគឺជាគំនិតមួយដែលអាចយកមកប្រើប្រាស់ក្នុងដំណើរការក្តីនៅមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ លក្ខន្តិកៈក្រុងរ៉ូមក៏ទទួលស្គាល់ផងដែរថាសេចក្តីសំរេច របស់អង្គបុរេ

---

19 អនុសញ្ញាទ្វីបអឺរ៉ុបដើម្បីការពារសិទ្ធិមនុស្សនិង សេរីភាពជាមូលដ្ឋាន (៤វិច្ឆិកា១៩៥០) ចូលជាធរមាននៅថ្ងៃទី ៣ កញ្ញា ១៩៥៣ ។

20 សូមមើលមាត្រា១៨ (៤) និងមាត្រា៨២ នៃលក្ខន្តិកៈក្រុងរ៉ូម ។

00195899

C221/138



ជំនុំជម្រះ អាចបណ្ដាលឱ្យមានការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិចូលរួមក្នុងដំណើរការនីតិវិធី ។ ដូច្នេះវាផ្ទុកទៅដោយ ការការពារ តាមផ្លូវច្បាប់មួយប្រឆាំងទល់នឹងការសំរេចចិត្តទាំងនោះ ។ ពាក់ព័ន្ធបញ្ហានេះកង្វះខាតការការពារ តាមផ្លូវច្បាប់ក្នុង ច្បាប់ពាក់ព័ន្ធសំរាប់អង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានគេមើលឃើញថាជា ចំណុចខ្វះខាតប្រហោងមួយ។

## IV. ការសង្កេតមើលលើផលវិបាកផ្សេងៗទៀត ប្រឆាំងនឹងដើមបណ្ដឹងរដ្ឋប្បវេណី និងសហ មេធាវី របស់ពួកគេ

២២. ដើមបណ្ដឹងរដ្ឋប្បវេណីក៏ត្រូវបានរើសអើងតាមរយៈការផ្ដល់ពេលវេលាសំរាប់ការធ្វើសន្និដ្ឋានផ្ទាល់មាត់ តិចជាងភាគីចុងចោទ និងអយ្យការ នៅក្នុងសវនាការកន្លងមកនេះ។ ខណៈដែលសហមេធាវីការពារជនជាប់ចោទ និង សហព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតិពេលវេលាឱ្យនិយាយរយៈពេល៩០នាទី នោះសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ របស់សហមេធាវីនៃដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវកំណត់មកត្រឹមតែ៦០នាទី។

ទោះយ៉ាងណា បទបញ្ជាផ្ទៃក្នុងចែងថាដើមបណ្ដឹងរដ្ឋប្បវេណីមានស្ថានភាពជាគូក្ដីនៅក្នុងដំណើរការ រឿងក្ដីហើយមិនបានចែងអំពីចំណុចសំគាល់ណាមួយដែលបង្ហាញពីកំរិតនៃសារៈសំខាន់ទាបជាងភាគីដទៃនោះទេ ។ លើសពីនេះ បរិមាណពេលវេលាខ្លីជាងពិតជាមិនគ្រប់គ្រាន់នោះទេ ព្រោះដើមបណ្ដឹងរដ្ឋប្បវេណីមួយ ចំនួននិង /ឬសហមេធាវីត្រូវតែចែករំលែកពេលវេលាគ្នានិយាយ។

ដោយយោងតាមវិធាន២៣(១)(ក)នៃវិធានផ្ទៃក្នុង ដើមបណ្ដឹងរដ្ឋប្បវេណីទ្រទ្រង់ដល់អយ្យការ ។ ដូច្នេះ វាមិនយុត្តិធម៌ទេដែលផ្ដល់ពេលវេលាដល់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការសន្និដ្ឋានផ្ទាល់មាត់ មានរយៈពេលខ្លីជាង ភាគីដទៃទៀត ។

ទស្សនៈវិស័យរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមិនដូចគ្នានឹងអយ្យការទេ។ ដូច្នេះ ការប្រព្រឹត្តលំអៀងធ្ងន់ធ្ងរបែបនេះមិនមានភាពយុត្តិធម៌ទេទាំងតាមហេតុផលជាក់ស្ដែងនិងច្បាប់ពាក់ព័ន្ធមួយចំនួន។

២៣. ការរើសអើងនេះដែលបានកំណត់ក្នុងកាលវិភាគនៃសវនាការមុនៗ បានមានលក្ខណៈកាន់តែអាក្រក់ ទៅៗដោយការអនុវត្តជាក់ស្ដែង ដូចបានឃើញនៅក្នុងសវនាការថ្ងៃទី២១ឧសភា២០០៨ នេះស្រាប់ ។ ទោះបីជា សហមេធាវីរបស់ភាគីជនត្រូវចោទ ក៏ដូចជាសហព្រះរាជអាជ្ញាបានចំណាយពេលក្នុងការនិយាយលើស ពីថេរវេលា កំណត់គួរឱ្យកត់សំគាល់ ហើយពួកគេនិយាយអ្វីតែដដែលៗក៏ដោយ ក៏ប្រធានអង្គជំនុំជំរះមិនមានធ្វើការទូន្មានអ្វីដែរ។ ផ្ទុយទៅវិញមានតែសហមេធាវីនៃដើមបណ្ដឹងរដ្ឋប្បវេណីទេ

00195900

E221/138



ដែលមុនពេលឡើងនិយាយ ត្រូវបានប្រធានអង្គជំនុំជំរះ ទូន្មានឱ្យនិយាយតាមថេរវេលាកំនត់ក្នុងកាលវិភាគ ហើយមិនឱ្យនិយាយអ្វី ដែលច្រំដែល។

២៤. ម្យ៉ាងទៀតការអនុវត្តយ៉ាងតឹងរឹងនូវសេចក្តីបង្គាប់បញ្ជាឱ្យអនុវត្ត(?)ដែលត្រូវបានកែសំរួល

នៅ ថ្ងៃទី ១៩ មេសា ២០០៨ បណ្តាលឱ្យមានការរើសអើងប្រឆាំងនឹងដើមបណ្តឹងរដ្ឋប្បវេណី។ សេចក្តីបង្គាប់

បញ្ជា ឱ្យ អនុវត្តតំរូវនៅក្នុងប្រការ៧, ២ ថា រាល់ឯកសារទាំងអស់ត្រូវរៀបចំជាភាសាខ្មែរ និង ភាសា(ផ្លូវការ) មួយទៀត។

ពិតហើយ វិធាននេះជាអាជ្ញាបញ្ជាដល់គ្រប់ភាគីទាំងអស់នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជា ។ ប៉ុន្តែបើគិតដល់បញ្ហាដែលថាដើមបណ្តឹងរដ្ឋប្បវេណីមិនបានទទួលមូលនិធិឬការទ្រទ្រង់សំរាប់ការបកប្រែ ឯកសារ នោះយើងឃើញថាមធ្យោបាយនេះមានលក្ខណៈរើសអើង ។

២៥. ការរាប់កាលបរិច្ឆេទកំណត់ដល់ចុងក្រោយមុនអង្គបុរេជំនុំជម្រះ ដែលក្នុងនោះមានកាលបរិច្ឆេទ ជូនដំណឹង ថ្ងៃចុងសប្តាហ៍ និងថ្ងៃឈប់សំរាកផ្លូវការ និងការកំណត់ពេលវេលាចុងក្រោយនៅម៉ោង ៤ រសៀល រាល់ថ្ងៃធ្វើការ ឬ ម៉ោង៣និង៣០នាទីរសៀលនាថ្ងៃសុក្រ និងរួមផ្សំជាមួយកាតព្វកិច្ចត្រូវបំពេញឯកសារជា ២ភាសាហើយដើមបណ្តឹងរដ្ឋប្បវេណីខ្វះធនធានផងនោះ នេះគឺជាការរើសអើងហើយ។

ហេតុដូច្នេះ ដោយបានគិតពិចារណាអំពីការរើសអើងដែលបានកើតឡើង សហមេធាវីនៃដើមបណ្តឹង រដ្ឋប្បវេណីសូមសំណូមពរឱ្យ ៖

(១) ពិចារណានូវការលើកឡើងខាងលើ ហើយទប់ស្កាត់កុំឱ្យមានទង្វើរើសអើងនាពេលអនាគត ដូច ជាការជំរុះចេញនូវសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឬការប្រព្រឹត្តមិនស្មើភាពគ្នាចំពោះ ពេលវេលាដែលបានផ្តល់ឱ្យ។

(២) ផ្តល់ការគោរពដល់ស្ថានភាពស្មើគ្នានៃដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការរឿងក្តីនៅមុខអង្គជំនុំ ជម្រះវិសាមញ្ញនៃតុលាការកម្ពុជា។

(៣) ទទួលស្គាល់ភាពសំខាន់ចាំបាច់នៃ ការការពារតាមផ្លូវច្បាប់ទល់នឹងសេចក្តីសំរេច សេចក្តីណែនាំ ឬ ដីកាផ្សេងៗទៀតរបស់អង្គបុរេជំនុំជម្រះ ដែលអាចរំលោភបំពានលើសិទ្ធិរបស់ភាគី ហើយដែលកើត ឡើងជាលើក ដំបូងនៅចំពោះមុខអង្គបុរេជំនុំជម្រះ។

ដោយសេចក្តីគោរពពី

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

មេធាវី ហុង គឹមសួន　　មេធាវី យុង ផានិត　　មេធាវី គង់ ពិសី

មេធាវីអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

មេធាវី ឡោ ជុនធី　　មេធាវី នី ចាន់ឌី　　កញ្ញាមេធាវី Silke Studzinsky

មេធាវីអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា

ធ្វើនៅភ្នំពេញ ថ្ងៃទី16 ខែមិថុនា ឆ្នាំ២០០៨